រក្សាសិទ្ធិ © ពត៌មាន :
© ២00១ Project WorldReach © ២00១ SEAN
រក្សាសិទ្ធិគ្រប់យ៉ាង

បង្ហាត់បង្រៀន និង បង្កើនចំនួនបន្ត ®

Project WorldReach (T&M™ ព័ន្ធកិច្ចប្រតិបត្តិការ)
Dr. George Patterson, (អ្នកនិពន្ធកម្មវិធី)
SEAN អន្តរជាតិ

អាស័យដ្ឋានសំរាប់ទាក់ទង :
Project WorldReach PWR ™
474 - 800 - 15355 - 24th Ave
Surrey BC, Canada
V4A 2H9

E-mail: pwr@trainandmultiply.com
Website: http://www.trainandmultiply.com

039KH01A-01

ការប្រដៅទូន្មាន
ដោយសេចក្តីស្រឡាញ់



កូនស្បៃរំភៅសំរាប់បង្ហាត់បង្រៀនគ្រួគង្វាល

៣៩

បង្ហាត់បង្រៀន និង បង្កើនចំនួនបន្ត ®

T&M ™

ទូលសូមអោយព្រះជាម្ចាស់ប្រទានប្រាជ្ញា ក្នុងការប្រដៅទូន្មានអ្នក
ដទៃ ។

ការប្រដៅទូន្មានជាកិច្ចការឃ្វាលមួយ ។ គ្រូគង្វាលខ្លះកសាង
សមាជិករបស់ខ្លួនអោយរីកចំរើនឡើងបាន ដោយសារផ្តល់ដំបូន្មាន
ច្រើនជាង ដោយសារអធិប្បាយ ។ ការដែលគ្រូគង្វាលផ្តល់ដំបូន្មាន
ដោយផ្ទាល់ ដល់មនុស្សដែលមានបញ្ហា ដើម្បីបង្រៀនគេអោយ
ចេះយកព្រះបន្ទូលរបស់ព្រះជាម្ចាស់មកអនុវត្ត សំរាប់ដោះស្រាយ
បញ្ហាផ្ទាល់ខ្លួនរបស់ពួកគេ ច្រើនតែមានលទ្ធផលល្អជាងការ
អធិប្បាយអំពីបញ្ហាទាំងនោះ ។

តើយើងត្រូវផ្តល់ដំបូន្មានទៅពេលណា ?



កិច្ចការដែលត្រូវអនុវត្ត

- ផ្តល់ដំបូន្មានអោយអស់អ្នកណា ដែលស្វែងរកជំនួយសំរាប់
ដោះស្រាយបញ្ហា ឬ ស្ថានភាពរបស់ពួកគេ ។
- បង្ហាត់បង្រៀនអ្នកទទួលខុសត្រូវឯទៀត ឱ្យចេះផ្តល់ដំបូន្មាន
ដោយប្រើកូនសៀវភៅសំរាប់បង្ហាត់បង្រៀននេះ ។
- សូមសរសេរឈ្មោះពួកអ្នកដែលនឹងជួយអ្នក ក្នុងការធ្វើ
កិច្ចការបំរើនេះ :

© Project WorldReach © SEAN

តើអ្នកអាចជួយពួកគេអោយអាចយកព្រះបន្ទូលទៅអនុវត្តក្នុងជីវិតពួកគេ ដោយរបៀបណា ? ។





មនុស្សទាំងអស់នោះហើយ ដែលត្រូវការដំបូន្មាន ។

យើងផ្តល់ដំបូន្មានដោយផ្ទាល់ចំពោះ :

- មនុស្សដែលមានបញ្ហាផ្ទាល់ខ្លួន
- គូដណ្តឹងដែលជិតរៀបការ
- មនុស្សដែលកំពុងកាន់ទុក្ខ
- មនុស្សឈឺ
- មនុស្សដែលធ្លាក់ទឹកចិត្ត
- មនុស្សដែលវង្វេងចេញពីព្រះជាម្ចាស់ ។



បើសិនជាមនុស្សដែលមានបញ្ហាខាងព្រលឹងវិញ្ញាណ មិនមានអ្នកណាផ្តល់ជំបួន្ទានគ្រប់គ្រាន់សព្វគ្រប់ដល់គេទេ អ្នកនោះមុខជាអស់សង្ឃឹម រហូតអាចធ្វើអំពើផ្តេសផ្តាស់បាន ។

ព្រះយេស៊ូគ្រីស្តបានផ្តល់ជំបួន្ទានដោយផ្ទាល់ ដល់មនុស្សជាច្រើន ដូចជាលោកនីកូដេម ស្ត្រីសាសន៍សាម៉ារី យុវជនអ្នកមានម្នាក់ លោកពេត្រុស លោកសាខេ នាងម៉ាថា និង មនុស្សជាច្រើននាក់ទៀត ។

អ្នក និង សមាជិករបស់ក្រុមជំនុំអ្នក ក៏អាចជួយមនុស្សដែលមានបញ្ហា នៅក្នុងសង្កាត់របស់អ្នកដែរ ។

នៅក្នុងចំណោមសេចក្តីទាំងឡាយ ដែលមានរៀបរាប់ជាបន្តបន្ទាប់ទាំងនេះ សូមគូសសញ្ញា «✓»នេះ នៅក្នុងវង់ក្រចក ដើម្បីសំគាល់បញ្ហា ដែលកើតមានច្រើនជាងគេ នៅម្តុំផ្ទះរបស់អ្នក :

☐ ការប្រមឹកស្រា ឬ ឥទ្ធិពលអាក្រក់នៃការប្រមឹកស្រា ។



តើអ្នកអាចជួយពួកគេអោយរកឃើញឫសគល់នៃបញ្ហានេះ ដោយរបៀបណា ? ។

តើអ្នកអាចជួយពួកគេអោយអាចធ្វើអោយទំនាក់ទំនងរបស់ពួកគេជាមួយព្រះជាម្ចាស់ប្រសើរឡើងវិញ ដោយរបៀបណា ? ។

© Project WorldReach © SEAN

ដើម្បីរកអោយឃើញបូសគល់នៃបញ្ហា កុំចាប់អារម្មណ៍ខ្លាំងទៅលើ :

□ ការនិយាយរ៉ាយរ៉ាប់សើៗមិនស៊ីជំរៅ ។

□ បូសគល់នៃបញ្ហា ។

ការនិយាយរ៉ាយរ៉ាប់សើៗ ជួនកាលបិទបាំងមូលហេតុពិត ដែលជាបូសគល់ជ្រៅនៃបញ្ហា ។ បូសគល់ជ្រៅនេះ អាចរកឃើញដោយ :

□ សួរសំនួរឈ្លាសវៃ និង ស្រាវជ្រាវ ។

□ ស្តីបន្ទោសទាល់តែពួកគេស្រែកយំ ។

យើងសួរសំនួរ និង ស្តាប់ដោយអំណត់ ។ បើសិនជាអ្នកនោះជាអ្នកជឿ យើងត្រូវជួយគាត់ស្វែងរក និង ទទួលព្រះហឫទ័យព្រះជា-ម្ចាស់សំរាប់គាត់ ទោះជាព្រះហឫទ័យនោះដូចម្តេចក៏ដោយ ។

សូមសរសេរកិច្ចការបីយ៉ាងដែលអ្នកផ្តល់ជំបូន្មាន ត្រូវជួយមនុស្សដែលទទួលជំបូន្មាននោះ ។ ឧទាហរណ៍ ប្តីប្រពន្ធពីរនាក់ រៀបចំលែងលះគ្នា ។ ប្រពន្ធប្តឹងពីប្តីថា គាត់ជាមនុស្សប្រមឹក ។ ឯចំណែកប្តីវិញនិយាយថា ប្រពន្ធគាត់ធ្វើអោយគាត់ធឹកស្រា ដោយសារនាងរអ៊ូរទាំច្រំដែលៗពេក ។

□ ការគ្មានការងារធ្វើ ។



□ ការមិនសូវប្រៀនប្រដៅកូនៗ ។



☐ ការឈ្លោះទាស់ទែងគ្នា ការច្រណែន ប្រច័ណ្ឌគ្នា ការមិនទុកចិត្តគ្នា និង បញ្ហាផ្សេងៗទៀត ។



យើងក៏ត្រូវផ្តល់ដំបូន្មាន អំពីការរីកចំរើនក្នុងព្រះគ្រីស្តដែរ ។ យើងមិនចាំបាច់រង់ចាំទាល់តែមនុស្សមានបញ្ហាខ្លាំង ទើបផ្តល់ដំបូន្មានដល់គេនោះទេ ។ ការដែលប្រសើរ គឺយើងត្រូវដោះស្រាយបញ្ហា ទោះជាបញ្ហានោះតូចតាចក៏ដោយ ។ ធ្វើដូចនេះទើបយើងអាចយកឈ្នះលើបញ្ហាផ្សេងៗបាន ។



ការប្រឡង (សំនួរសង្ខេបមេរៀន)

តើយើងផ្តល់ដំបូន្មាន នៅពេលណា ?

☐ នៅថ្ងៃអាទិត្យ ក្រោយពេលថ្វាយបង្គំ ។

☐ នៅពេលដែលចាំបាច់ ។

សេចក្តីត្រូវការផ្ទាល់ខ្លួនរបស់មនុស្ស ត្រូវដោះស្រាយ :

☐ ជាសាធារណៈ ។

☐ មួយទល់នឹងមួយ ។

យើងពិភាក្សារឿងរ៉ាវផ្ទាល់ខ្លួន មួយទល់នឹងមួយ ។ បន្ទាប់មក អ្នកផ្តល់ដំបូន្មាន :

☐ ផ្សព្វផ្សាយអោយគេដឹងពេញក្រុមជំនុំ ។

☐ រក្សាការសំងាត់ ។

អ្នកផ្តល់ដំបូន្មានត្រូវរក្សាទុកជាសំងាត់នូវសេចក្តីទាំងឡាយ ដែលគេប្រាប់គាត់ ដោយសារទុកចិត្តគាត់ ហើយមិនប្រាប់ទៅអ្នកណាផ្សេង សូម្បីតែប្រពន្ធ ឬ ប្តីក៏មិនប្រាប់ផង ។

- ពេលចាកចេញពីផ្ទះ (ម៉ាថាយ ១០:១៦-២០, ម៉ាថាយ ២៨:១៩-២០, យ៉ូហាន ១៤:១-៤, លូកា ១៥:១១-៣២, ហេប្រឺ ១១:៨-១៦) ។
- ការការពាររបស់ព្រះជាម្ចាស់ (ម៉ាថាយ ១០:២៤-៣៣, ១១:២៨-៣០, រ៉ូម ៨:៣១-៣៩, ភីលីព ៤:១៩) ។
- គ្មានសេចក្តីសុខសាន្តក្នុងចិត្ត (លូកា ១០:៣៨-៤២, យ៉ូហាន ជំពូក ១៤, ១៦:២០, ១៦:២២-២៤, ១៦:៣៣, រ៉ូម ៥:១-៥, ភីលីព ៤:៦-៧, កូឡូស ៣:១៥) ។
- ការមានអារម្មណ៍ថាបរាជ័យ (ម៉ាថាយ ២៦:៣៣-៣៥, ២៦:៦៩-៧៥, យ៉ូហាន ២១:១៥-២២, រ៉ូម ៨:៣៥-៣៩, ១ កូរិនថូស ១០:១២-១៣, វិវរណៈ ជំពូក ២-៣) ។
- មារសាតាំងបរាជ័យ (រ៉ូម ១៦:២០, អេភេសូ ៦:១០-២០, កូឡូស ២:១៥, ហេប្រឺ ២:១៤-១៥, យ៉ាកុប ៤:៧, វិវរណៈ ២០:១០) ។

របៀបផ្តល់ដំបូន្មាន ដែលមានប្រសិទ្ធិភាព

យើងជួយពួកអ្នកដែលមានបញ្ហា អោយអាចធ្វើកិច្ចការបីយ៉ាង :

១- រកអោយឃើញមូលហេតុ ដែលជាឫសគល់នៃបញ្ហារបស់ពួកគេ :

(អ្នកផ្តល់ដំបូន្មានត្រូវស្តាប់មនុស្សនោះ និយាយពន្យល់អំពីបញ្ហារបស់ខ្លួន គឺដំបូងស្តាប់ពាក្យរអ៊ូរទាំប្តឹងផ្តល់ និង ពាក្យដែលបង្ហាញពីការព្រួយបារម្ភ ដែលមើលឃើញជាក់ស្តែងជាងគេ ។ បន្ទាប់មក ត្រូវសួរសំនួរសំខាន់ៗ ដើម្បីដឹងពីមូលហេតុ ដែលកប់បាត់ជ្រៅនៅក្នុងអតីតកាល) ។

២- ណែនាំពួកគេឱ្យសំរុះសំរួលទំនាក់ទំនងរបស់ពួកគេអោយជានានឹងព្រះជាម្ចាស់ :

(អ្នកផ្តល់ដំបូន្មានត្រូវជួយមនុស្សនោះ ឱ្យអាចទទួលសារភាពកំហុសចំពោះព្រះជាម្ចាស់ និង ទូលប្រាប់សេចក្តីត្រូវការរបស់គេថ្វាយទៅព្រះអង្គ ហើយជួយអ្នកនោះអោយអាចសារភាពកំហុស នៅចំពោះមុខអ្នកដែលគេបានធ្វើអាក្រក់ទៅលើ) ។

៣- យកសេចក្តីបង្រៀនក្នុងព្រះបន្ទូលរបស់ព្រះជាម្ចាស់មក អនុវត្ត ដើម្បីដោះស្រាយបញ្ហា :

(អ្នកផ្តល់ជំបូន្មានត្រូវជួយពួកគេអោយអាចដោះស្រាយបញ្ហា ដោយណែនាំគេអោយចេះពិចារណាអំពីបញ្ហា និង រៀបចំធ្វើសកម្មភាពដើម្បីដោះស្រាយបញ្ហា ស្របទៅតាមគោលការណ៍ក្នុងព្រះគម្ពីរ) ។

ការរំលឹកឡើងវិញ : អ្នកផ្តល់ជំបូន្មានល្អ ត្រូវចេះដឹកនាំមនុស្ស អោយរកឃើញ និង ដោះស្រាយមូលហេតុជាឫសគល់របស់បញ្ហារបស់ខ្លួន ថែមទាំងណែនាំគាត់អោយសំរុះសំរួលទំនាក់ទំនងរបស់គាត់អោយជានានឹងព្រះជាម្ចាស់ឡើងវិញ និង ណែនាំអោយគាត់ចេះយកសេចក្តីបង្រៀនក្នុងព្រះបន្ទូលរបស់ព្រះជាម្ចាស់មកអនុវត្ត ដើម្បីដោះស្រាយបញ្ហារបស់គាត់ ។

១- តើយើងណែនាំឱ្យ**គេរកឃើញមូលហេតុ ដែលជាឫសគល់នៃ**បញ្ហារបស់គេ ដោយរបៀបណា ? ។

_____

_____

_____

- ពេលព្រួយចិត្ត (ទំនុកតម្កើង ៣៤:១៩, ៥០:១៥, យ៉ូហាន ជំពូក ១៤, រ៉ូម ៨:២៨-២៩, ១ កូរិនថូស ១៥:៥១-៥៨, ២ កូរិនថូស ១:៣-៤, ១ ថែស្សាឡូនិក ៤:១៣-១៨, ហេប្រឺ ១២:៥-១៣, ១ ពេត្រុស ៥:៧) ។
- សារៈសំខាន់នៃការអរព្រះគុណព្រះជាម្ចាស់ជាប់ជានិច្ច នៅគ្រប់ស្ថានភាព (១ ថែស្សាឡូនិក ៥:១៨, ហេប្រឺ ១៣:១៥) ។
- ពេលមានទុក្ខវេទនា (ម៉ាថាយ ១១:២៨-៣០, យ៉ូហាន ១៤:១-៤, ហេប្រឺ ៧:២៥, ២ ពេត្រុស ២:៩) ។
- ពេលមានបន្ទុកធ្ងន់ (ម៉ាថាយ ១១:២៨-៣០, យ៉ូហាន ១៤:១-៤, រ៉ូម ៨:៣១-៣៩, ១ កូរិនថូស ១៥:៥៨, កាឡាទី ៦:៩-១០) ។
- ពេលដែលមិត្តភក្តិ ឬ អ្នកឯទៀតធ្វើអោយឈឺចាប់ ឬ ខកចិត្ត (ម៉ាថាយ ១០:២១-៣៩, លូកា ១៧:៣-៤, រ៉ូម ១២:១៤, ១៧, ១៩, ២១, ១ កូរិនថូស ជំពូក ១៣) ។

- ពេលមានជំងឺ ការឈឺចាប់ ឬ ទំនាស់ផ្លូវចិត្ត (ទំនុកតម្កើង ៤១:៤, ១០៣:៣, ម៉ាថាយ ២៦:៣៩, រ៉ូម ៥:៣-៥, ២ ធីម៉ូថេ ២:៣, ហេប្រឺ ១២:១-១១, យ៉ាកុប ៥:១១-១៦, ១ ពេត្រុស ៤:១៩) ។
- សេចក្តីអធិស្ឋានអំពីសេចក្តីត្រូវការ (អេសាយ ៤០:៣១, យេរេមី ៣៣:៣, ម៉ាថាយ ៦:៥-១៥, ១៨:១៩-២០, ម៉ាកុស ១១:២៤, លូកា ១១:១-១៣, ១៨:១-១៤, យ៉ូហាន ១៦:២៣ និង យ៉ូហាន ជំពូក ១៧, ១ យ៉ូហាន ៥:១៤-១៥) ។
- ការសង្គ្រោះ (រ៉ូម ៣:២៣, ៦:២៣, ៥:៨, ៦:២៣, ១០:៩, ជំពូក ១៣) អានតាមលំដាប់លំដោយនេះ ដើម្បីពន្យល់អំពីផែនការសង្គ្រោះ (យ៉ូហាន ៣:១៦, ៥:២៤, រ៉ូម ៣:២៨, ៤:៥) ។
- ការស្វែងរកព្រះជាម្ចាស់ (ទុតិយកថា ៤:២៩, សុភាសិត ៨:១៧, យេរេមី ៣១:៣, កិច្ចការ ១៧:២៧) ។
- ពេលមានវិបត្តិ (ម៉ាថាយ ៦:២៥-៣៤, ២ ធីម៉ូថេ ១:៧, ហេប្រឺ ៤:១៦, ១៣:៦) ។

២- តើយើងណែនាំអោយគេ**សំរុះសំរួលទំនាក់ទំនងរបស់គេ ឱ្យជានានឹងព្រះជាម្ចាស់** ដោយរបៀបណា ? ។

_____

_____

_____

_____

_____

_____

_____

៣- តើយើងណែនាំអោយគេ**យកសេចក្តីបង្រៀនក្នុងព្រះបន្ទូលរបស់ព្រះជាម្ចាស់មកអនុវត្ត** ដើម្បីដោះស្រាយបញ្ហារបស់គេដោយរបៀបណា ? ។

_____

_____

_____

_____

_____

_____

_____

© Project WorldReach © SEAN

រកអោយឃើញមូលហេតុ ដែលជាឫសគល់នៃបញ្ហារបស់ពួកគេ

នៅពេលចាប់ផ្តើមធ្វើការផ្តល់ដំបូន្មាន ត្រូវអធិស្ឋានទូលសូមអោយព្រះជាម្ចាស់ដឹកនាំ និង ប្រទានប្រាជ្ញាអោយអាចរកឃើញដំណោះស្រាយសំរាប់បញ្ហានោះ (យ៉ាកុប ១:៥) ។ ពេលផ្តល់ដំបូន្មានត្រូវប្រុងប្រៀបចាំស្តាប់សេចក្តី ដែលព្រះវិញ្ញាណដ៏វិសុទ្ធមានជាសតៀនក្នុងចិត្តរបស់អ្នក ។

ត្រូវស្តាប់ដោយប្រុងប្រយ័ត្ន មុននឹងផ្តល់ដំបូន្មាន ។ អ្នកផ្តល់ដំបូន្មាន ដែលគ្រាន់តែនិយាយ មិនព្រមស្តាប់ គ្មានបានលទ្ធផលល្អទេ ! ។

- ការឈ្នះលើការព្រួយបារម្ភ (ម៉ាថាយ ៦:២៥-៣៤, ភីលីព ៤:៦-៧, ហេប្រឺ ១៣:៥-៦, ១ ពេត្រុស ៥:៧, ២ ធីម៉ូថេ ៤:១៧-១៨) ។
- ការលើកលែងទោសអោយអ្នកដែលកែប្រែចិត្តគំនិត (ទំនុកតម្កើង ៣៤:១៨, ១០៣:១២, អេសាយ ១:១៨, ៥៣:៦, អេភេសូ ១:៧, ១ យ៉ូហាន ១:៩) ។
- នៅពេលប្រឈមមុខនឹងគ្រោះមហន្តរាយ (លូកា ៨:២២-២៥, ២ ធីម៉ូថេ ជំពូក ៣) ។
- ការធ្លាក់ទឹកចិត្ត (ម៉ាថាយ ៥:៤, ម៉ាថាយជំពូក ១១-១២, យ៉ូហាន ១៤:១-៣, ២ កូរិនថូស ៤:៨, ៤:១៦-១៨, ភីលីព ៤:៤-៧, ហេប្រឺ ១៣:៥-៦, ១ យ៉ូហាន ៣:១-៣) ។
- ពេលត្រូវល្បួង (ម៉ាថាយ ៦:២៤, ២៥:១-១៣, ម៉ាកុស ៩:៤៣-៥១, ១៣:៣៣-៣៧, លូកា ២១:៣៤-៣៦, រ៉ូម ១៣:១២-១៤, ១ កូរិនថូស ១០:១៣, ភីលីព ៤:៨, ហេប្រឺ ២:១៨, យ៉ាកុប ១:១២, ២ ពេត្រុស ២:៩, យូដាស ជំពូក ២៤-២៥) ។

អ្នកទទួលដំបូន្មាន មិនត្រូវចាត់ទុកព្រះបន្ទូលព្រះជាម្ចាស់ជាវត្ថុ
សក្តិសិទ្ធិ ដែលនាំអោយមានសំណាងល្អនោះទេ តែត្រូវទុកចិត្ត
លើព្រះជាម្ចាស់ផ្ទាល់ ដែលមានព្រះបន្ទូលនេះវិញ ។ នេះជាវគ្គ
គម្ពីរខ្លះ សំរាប់ប្រើក្នុងការផ្តល់ដំបូន្មាន :

- ការទូលសូមអោយព្រះជាម្ចាស់ពិនិត្យមើលចិត្តគំនិតរបស់
  អ្នក (ទំនុកតម្កើង ១៣៩:២៣-២៤) ។
- អត្ថបទសំខាន់អំពីជីវិតក្នុងព្រះគ្រីស្ត (រ៉ូម ជំពូក ៦-៨,
  ២ កូរិនថូស ៥:១៧, កូឡូស ២:៩-១០) ។
- ការទុកចិត្ត និង ជឿជាក់ (ភីលីព ៤:១៣, យ៉ូហាន
  ១០:២៧-២៨, រ៉ូម ៨:៣៨-៣៩, ២ ធីម៉ូថេ ១:៧,
  ទំនុកតម្កើង ជំពូក ២៧, អេសាយ ២៦:៣, ៤០:៣១,
  អេភេសូ ៣:២០-២១) ។
- ការឈ្នះលើការភ័យខ្លាច (យ៉ូហាន ១១:១៧-៤៤, និង
  យ៉ូហាន ជំពូក ១៧ និង ជំពូក ២០, រ៉ូម ជំពូក ៨,
  ១ កូរិនថូស ១៥:៥១-៥៨, ២ កូរិនថូស ៤:៨-១៨,
  ៥:១-៨, ១២:៩, ហេប្រឺ ២:១៤-១៥, ១៣:៦) ។

អ្នកផ្តល់ដំបូន្មានឥតចាន់ការ :



«...ត្រូវកែតំរង់អ្នកនោះ ដោយចិត្តស្លូតបូត» (កាឡាទី ៦:១) ។

គោលបំណងនៃការផ្តល់ដំបូន្មាន គឺស្វែងរក«ឫសគល់នៃបញ្ហា» ។ បើសិនជាអ្នកផ្តល់ដំបូន្មាន និង មនុស្សមានបញ្ហា គ្រាន់តែដោះស្រាយតែសញ្ញាខាងក្រៅរបស់បញ្ហានោះ ស្ថានភាពរបស់មនុស្សនោះ នៅតែមិនអាចប្រសើរឡើងជដែល គឺថា នៅតែមានទុក្ខលំបាក ។ ឧ. ការប្រមឹកស្រាជា «សញ្ញាជាក់ស្តែង »នៃបញ្ហាមួយ ឯមូលហេតុទាំងឡាយ ដែលបណ្តាលឱ្យមនុស្សម្នាក់ប្រមឹកស្រាជ្រុល គឺជា«ឫសគល់លាក់កំបាំង »នៃបញ្ហា ។ ប្រហែលជាមនុស្សនោះធឹកស្រា ដោយសារតែគាត់ចេះតែនឹកឃើញពីការស្លាប់យ៉ាងអណោចអធម្មរបស់ប្រពន្ធ និង កូនគាត់ ពេលសង្គ្រាម។ ការនឹកឃើញជាប់ជានិច្ចពីអ្វីៗដែលអាក្រក់នេះ គឺជា«ឫសគល់លាក់កំបាំង »នៃបញ្ហា ។ អ្នកផ្តល់ដំបូន្មានត្រូវណែនាំមនុស្សនោះអោយដោះស្រាយបញ្ហាប្រមឹកស្រា ហើយនិងបញ្ហាចេះតែនឹកឃើញពីសោកនាដកម្ម ព្រមគ្នា ទើបអាចជួយមនុស្សនោះឱ្យកែខ្លួនបាន ។

វគ្គព្រះគម្ពីរសំរាប់ស្ថានភាពផ្សេងៗ

ការរិះគិតអំពីវគ្គមួយនៃព្រះគម្ពីរជារៀងរាល់ថ្ងៃ មានប្រយោជន៍ណាស់ ។ ព្រះបន្ទូលសន្យារបស់ព្រះជាម្ចាស់សំខាន់ណាស់ ព្រោះជាព្រះបន្ទូលដែលមានជីវិត និង ឫទ្ធានុភាព ។ បើសិនជាអ្នកណាម្នាក់យល់ជ្រួតជ្រាបព្រះបន្ទូលសន្យាទាំងនោះ ព្រះវិញ្ញាណរបស់ព្រះជាម្ចាស់នឹងធ្វើឱ្យព្រះបន្ទូលសន្យាទាំងនោះ បានសំរេចនៅក្នុងជីវិតអ្នកនោះ ។ ព្រះបន្ទូលសន្យាទាំងនោះ នឹងជួយគេពេលមានទុក្ខលំបាក ។ ព្រះគម្ពីរចែងថា÷ *«ត្បិតព្រះបន្ទូលរបស់ព្រះជាម្ចាស់ ជាព្រះបន្ទូលដ៏មានជីវិត និង មានមហិទ្ធិឫទ្ធិមុតជាងដាវមុខពីរទៅទៀត »* (ហេប្រឺ ៤:១២) និង *« រីឯពាក្យរបស់យើងក៏ដូច្នោះដែរ គឺពាក្យដែលចេញពីមាត់របស់យើងនឹងមិនវិលត្រឡប់មករកយើងវិញឡើយ ដរាបណាទាល់តែបានសំរេចតាមបំណងរបស់យើងជាមុនសិន គឺបំពេញកិច្ចការ ដែលយើងចាត់ឱ្យមកធ្វើរួចរាល់សព្វគ្រប់ »* (អេសាយ ៥៥:១១) ។

ត្រូវអោយវគ្គព្រះគម្ពីរទៅអ្នកដែលស្តាប់ដំបូន្មាន សំរាប់រិះគិតពិចារណាផង និង ផ្តល់ដំបូន្មានដល់គាត់ តាមរបៀបផ្សេងៗផង ។ ធ្វើកិច្ចការទាំងពីរនេះរួមគ្នា ទើបមានប្រសិទ្ធិភាព ។

ដើម្បីរៀនថែមទៀតអំពីការផ្តល់ដំបូន្មានដល់អ្នកឈឺ និង អំពីការ
រំដោះមនុស្សដែលខ្មោចចូល សូមមើលក្នុងសៀវភៅសំរាប់បង្ហាត់
បង្រៀនគ្រូគង្វាល ទី ៣៨ «ជួយសំរាលទុក្ខអ្នកជំងឺ » និង ទី
៥៧ «ការយកឈ្នះលើសេចក្តីងងឹត » ។

ត្រូវសុំអោយអ្នកជំនែជួយ ក្នុងករណីដែលមានការលំបាកខ្លាំង

បើសិនជាអ្នកមិនយល់ថា ឫសគល់របស់បញ្ហាជាអ្វី ឬ ដំបូន្មាន
របស់អ្នកពិតជាមិនអាចដោះស្រាយបញ្ហាបាន អ្នកត្រូវសុំជំនួយពី
គ្រូគង្វាល ដែលមានបទពិសោធន៍ច្រើនជាង ឬ ពីគ្រូពេទ្យជំនាញ
ខាងជំងឺផ្លូវចិត្ត ដែលជាគ្រីស្តជន ឬ គ្រូពេទ្យ ស្របទៅតាមសេចក្តី
ត្រូវការ ។ ការដែលអ្នកចេះទទួលស្គាល់ពីកំរិតសមត្ថភាពរបស់
ខ្លួន និង ពីអំណោយទានរបស់អ្នកជំនែ ជាសក្ខីភាពបង្ហាញថា អ្នក
មានកំរិតចាស់ទុំខាងព្រលឹងវិញ្ញាណហើយ ។ បើយើងចេះយល់
ដូច្នោះ យើងអាចចៀសវាងមិនបង្ខាតពេលវេលា និង មិនទុកឱ្យ
មនុស្សមានបញ្ហារងការឈឺចាប់យូរតទៅទៀត ។

អ្នកផ្តល់ដំបូន្មាន ត្រូវខិតខំស្តាប់ ដើម្បីស្វែងរកឱ្យឃើញឫសគល់
នៃបញ្ហា ។ អ្នកផ្តល់ដំបូន្មានមិនត្រូវគិតស្មានថា ពាក្យរ៉ាយរ៉ាប់
ប្តឹងផ្តល់របស់អ្នកទទួលដំបូន្មាន អាចបង្ហាញពីបញ្ហាពិតនោះទេ ។
ឧទាហរណ៍ សុភាពនិយាយថា ចៅហ្វាយរបស់គាត់ និង អ្នកធ្វើ
ការជាមួយគាត់ឯទៀត មិនស្មោះត្រង់នឹងគាត់ទេ ។ ប៉ុន្តែ នៅ
ពេលដែលអ្នកផ្តល់យោបល់ សួរសំនួរច្រើនតទៅទៀត អ្នកផ្តល់
យោបល់ក៏ដឹងថា សុភាពច្រណែននឹងមិត្តម្នាក់ ដែលធ្វើការជា-
មួយគាត់ ពីព្រោះមិត្តម្នាក់នោះត្រូវចៅហ្វាយតម្លើងឋានៈអោយធ្វើ
ជាប្រធានបុគ្គលិក ។ ចៅហ្វាយមិនបានជ្រើសរើសសុភាពអោយ
ធ្វើជាប្រធានទេ ព្រោះសុភាពតែងតែមកធ្វើការយឺត ហើយឆាប់
ចេញមុនម៉ោងពេក ។ ដូចនេះ អ្នកផ្តល់ដំបូន្មាននេះ បានរក
ឃើញឫសគល់នៃបញ្ហាសុភាពនៅកន្លែងធ្វើការ ។

អ្នកផ្តល់ដំបូន្មានបានសួរសំណួរច្រើនបន្តទៀត ដើម្បីអាចរកឃើញមូលហេតុ ដែលនាំឱ្យសុភាពក្លាយជាបុគ្គលិកគ្មានសមត្ថភាព ។ សុភាពនិយាយប្រាប់គាត់អោយដឹងថា ឱពុកម្តាយសុភាពជាអ្នកមាន ហើយមានអ្នកបំរើចាំធ្វើការងារក្នុងផ្ទះគ្រប់យ៉ាង ។ ដូច្នេះ ហើយ ទើបសុភាពមិនស្គាល់តំលៃនៃការឧស្សាហ៍ព្យាយាម ។ ដូច្នេះ បញ្ហាពិតរបស់សុភាព គឺគាត់ខ្វះសីលធម៌ក្នុងការងារ (គឺគាត់មិនយល់របៀបធ្វើការងារ និង តំលៃការងារ) ដែលបណ្តាលឱ្យគាត់ក្លាយជាមនុស្សខ្ជិលធ្វើការងារ ។ ចៅហ្វាយមិនតំឡើងថានៈអោយគាត់ ដោយសារគាត់មកធ្វើការយឺតយ៉ាវ ។ សុភាពក្លាយជាមនុស្សមានចិត្តច្រណែននឹងបុគ្គលិកធ្វើការជាមួយ ដែលចៅហ្វាយអោយឡើងជាប្រធានបុគ្គលិក ។ ការរអ៊ូរទាំដំបូងរបស់សុភាពថា «ចៅហ្វាយខ្ញុំ និង អ្នកធ្វើការជាមួយខ្ញុំមិនស្មោះត្រង់នឹងខ្ញុំ »នោះ មិនមែនជាបញ្ហាពិតទេ ។

មនុស្សជាច្រើនមិនទទួលស្គាល់ ឬ មិននិយាយពីមូលហេតុពិតរបស់បញ្ហាពួកគេទេ ។ អ្នកផ្តល់ដំបូន្មានត្រូវយល់ថា តាមធម្មតាបញ្ហាច្រើនតែមានមូលហេតុលាក់កំបាំង ។ ដូច្នេះ អ្នកផ្តល់ដំបូន្មានត្រូវសួរសំនួរជាច្រើន ដើម្បីអាចរកឃើញរឿងពិត ។

ដើម្បីអោយមនុស្សបានរួចពីអារក្ស

ប្រកាសប្រាប់អំពីទ្ធានុភាពរបស់ព្រះគ្រីស្តលើអារក្ស (ម៉ាកុស ៥:១-២០, អេភេស្ស ៦:១០-១៨, វិវរណៈ ជំពូក ១២, កូឡូស ២:១៥) ក្នុងករណី ដែលមនុស្សមានជាប់ទាក់ទងជាមួយ ឬ នៅក្រោមឥទ្ធិពលនៃ :

- អបិយ៍ជំនឿ (មន្តអាគម អាបធ្មប់ ការអន្ទងព្រលឹងខ្មោច ការទស្សន៍ទាយ ។ល។) ។
- ការគាបសង្កត់ ដោយសារវិញ្ញាណអាក្រក់ ឬ ខ្មោចចូល ។
- អំពើបាបដែលធ្វើអោយក្លាយជាទាសករ (ការញៀន) ដូចជាការរួមភេទដូចគ្នា ការប្រមឹកស្រា ការញៀនគ្រឿងញៀន អំពើប្រាសចាកសីលធម៌ ការលោភលន់ អំនួត ការស្អប់គ្នា ការច្រណែនឈ្នានីសគ្នា ។ល។ ។
- របួសផ្លូវចិត្តខ្លាំងពេក ដែលដំបូន្មានរបស់មនុស្សធម្មតា ឬ ការខំប្រឹងកែប្រែខ្លួនឯង មិនអាចធ្វើអោយបាត់ការឈឺចាប់នោះបាន ។

អោយពួកគេមានបញ្ហា ។ ព្រះជាម្ចាស់នឹងរំដោះយើង មិនត្រឹមតែឱ្យរួចពីទោសនៃអំពើបាប និង ការញៀនប៉ុណ្ណោះទេ គឺថែមទាំងប្រោសយើងឱ្យបានជាពីរបួសផ្លូវចិត្ត ដែលបណ្តាលមកពីមនុស្សឯទៀតធ្វើអំពើបាបមកលើយើងដែរ ។

ដើម្បីជួយមនុស្សដែលធ្លាក់ទឹកចិត្ត

ធ្វើអោយពួកគេទុកចិត្តថា ព្រះជាម្ចាស់ស្រឡាញ់ពួកគេជានិច្ច ។ អ្នកអាចប្រើប្រស្នាអំពីកូនពៅដែលវង្វេងនៅក្នុង លូកា ១៥:១១-៣២ ឬ ប្រើអេភេសូ ៣:១៤-២១ ដើម្បីណែនាំឱ្យពួកគេទុកចិត្តលើសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ ។ នៅក្នុងគម្ពីរ យ៉ូហាន ១៤:២៧ ព្រះយេស៊ូមានបន្ទូលសន្យាថា នឹងប្រទានសេចក្តីសុខសាន្តអស់កល្បរបស់ព្រះអង្គដល់យើង ។

ដើម្បីអោយមនុស្សបានរួចពីបំណងអាក្រក់ទាំងឡាយ

អាចប្រើ រ៉ូម ៨:៥-១៧ ឬ កាឡាទី ៥:១៦-២៥ ដើម្បីនាំពួកគេអោយអាចឈ្នះលើបំណងអាក្រក់ និង ទំលាប់អាក្រក់ទាំងឡាយបាន ។

នេះជាឧទាហរណ៍មួយអំពីការផ្តល់ដំបូន្មានអោយសុភាព :

សញ្ញាជាក់ស្តែង :

(សុភាពខកចិត្ត ដូចនេះទើបរអ៊ូរទាំ) : «នៅកន្លែងធ្វើការរបស់ខ្ញុំគ្មានមនុស្សស្មោះត្រង់ទេ ! ចៅហ្វាយខ្ញុំ និង អ្នកធ្វើការឯទៀតសុទ្ធតែជាមនុស្សអាក្រក់ ! » ។

មូលហេតុបន្ទាប់បន្សំ :

(សុភាពមានការច្រណែន) : «ថ្ងៃនេះ ចៅហ្វាយខ្ញុំបានតម្លើងឋានៈអោយអ្នកធ្វើការជាមួយខ្ញុំម្នាក់ ធ្វើជាប្រធាន ។ គាត់គួរតែជ្រើសរើសខ្ញុំធ្វើជាប្រធានវិញ ។

មូលហេតុដំបូង :

(គ្រួសារសុភាពមិនដែលបង្រៀនសុភាព អោយចេះស្គាល់តំលៃនៃការខ្សាហ៍ព្យាយាមធ្វើការងារទេ) : សុភាពធ្លាប់មានអ្នកបំរើច្រើននាក់ចាំធ្វើអ្វីៗគ្រប់យ៉ាងអោយគាត់ ។ ហេតុនេះហើយ ទើបពេលធំឡើង សុភាពមិនចេះព្យាយាមធ្វើការងារទេ ។ គាត់ជាមនុស្សខ្ជិល តែចង់បានឋានៈខ្ពង់ខ្ពស់ក្នុងក្រុមហ៊ុន ឬ អង្គការផ្សេងៗ ។

© Project WorldReach © SEAN

យើងនឹងមើលពីឧទាហរណ៍ខ្លះអំពីសញ្ញាសំគាល់ជាក់ស្តែងរបស់បញ្ហា និង មូលហេតុរបស់បញ្ហា ។

មូលហេតុដែលមានដាក់ជូននៅខាងក្រោមនេះ គ្រាន់តែជាឧទាហរណ៍ប៉ុណ្ណោះ ។ សញ្ញាខាងក្រោមនេះអាចបណ្តាលមកពីមូលហេតុផ្សេងៗជាច្រើនទៀត ។

សញ្ញាជាក់ស្តែង	**មូលហេតុ ដែលជាឫសគល់លាក់កំបាំង**
ការប្រមឹកស្រា	- ដោយសារគាត់ភរប្រពន្ធ មនសិការគាត់ឈឺចាប់ ។ - ឪពុកគាត់ដាក់ទោសគាត់ ហួសហេតុកាលគាត់នៅពីកុមារ ហេតុនេះហើយបានជាគាត់ការពារខ្លួន ដោយភរ ។
ចង់លែងលះគ្នា	- មិនចេះស្រឡាញ់ មិនចេះអត់ទោស និងមិនទុកចិត្តប្រពន្ធខ្លួន ។ - ឪពុកម្តាយគាត់តែងតែឈ្លោះប្រកែកគ្នា ហើយមិនយល់ចិត្តគ្នាទៅវិញទៅមក ។

- សំរេចចិត្តលះបង់ឈប់មានទំនាក់ទំនងអសីលធម៌ទៀត ។
- យល់ព្រមទទួលជំបួន្ទានខាងព្រលឹងវិញ្ញាណ ព្រមទាំងបន្តរាយការណ៍អំពីការរីកចំរើននៃការផ្តល់ជំបួន្ទាន ឬ អំពីបញ្ហារហូតដល់មនុស្សអាចមានការប្រព្រឹត្តថ្មីជាស្ថាពរ ។

អ្នកផ្តល់ជំបួន្ទាន ក៏ត្រូវផ្តល់ជំបួន្ទានអោយអ្នកដែលរងគ្រោះគ្មានកំហុស ដោយសារការធិតក្បត់នេះដែរ ។ យើងជួយទាំងអ្នកនេះអោយអាចជឿជាថា នៅមានអ្នកដែលស្រឡាញ់ពួកគេទៀត និង ឱ្យអ្នកទាំងនេះ ទុកចិត្តខ្លួនឯងបានថា ពិតជាបានព្រះយេស៊ូគ្រីស្តរំដោះ និង ប្រោសមុខរបួសផ្លូវចិត្តអោយជា តាមរយៈព្រះវិញ្ញាណដ៏វិសុទ្ធ (រ៉ូម ១២:១២, ១២:១៥-២១) ។

ដើម្បីអោយមនុស្សអាចជាសះស្បើយពីរបួសខាងផ្លូវចិត្ត

លើកទឹកចិត្តពួកគេឱ្យជឿទុកចិត្តលើវត្តមាន និង ឫទ្ធានុភាពរបស់ព្រះជាម្ចាស់ (អេសាយ ៤១:១០, ១ កូរិនថូស ១៥:១០) ។ ប្រាប់ពួកគេថា ព្រះជាម្ចាស់រំដោះយើងអោយរួចពីការភ័យខ្លាច (អេសាយ ៤៣:១, ១ យ៉ូហាន ៤:១៨, ២ ធីម៉ូថេ ១:៧, ទំនុកតម្កើង ២៧:១) ។ ពួកគេអាចជាពី «របួសផ្លូវចិត្ត» បានលុះត្រាតែព្រះជាម្ចាស់ប្រោសឱ្យជារបួសផ្លូវចិត្ត ដែលបន្តបណ្តាល

- ប្តីត្រូវស្រឡាញ់ប្រពន្ធដូចព្រះគ្រីស្តស្រឡាញ់ក្រុមជំនុំដែរ ។ មិនមែនបង្ខំប្រពន្ធអោយចុះចូលនឹងខ្លួនទេ តែត្រូវស្រឡាញ់ និង ថែរក្សានាង ដើម្បីអោយនាងស្ម័គ្រចិត្តចុះចូលនឹងខ្លួនដោយខ្លួននាងផ្ទាល់ (អេភេសូ ៥:២៥-៣៣) ។
- ប្តីត្រូវចំណាយពេលយ៉ាងតិចមួយថ្ងៃ រាល់អាទិត្យ សំរាប់នៅជាមួយគ្រួសារ (ឬ អោយបានចំនួនស្មើ) ដើម្បីបង្ហាញការថ្នាក់ថ្នមស្រឡាញ់ចំពោះប្រពន្ធ និង កូនម្នាក់ៗ និង ដើម្បីធ្វើកិច្ចការជាមួយគ្នា ដូចជាលេងល្បែង ចេញទៅហូបបាយនៅទីវាល ធ្វើសកម្មភាពកំសាន្តអ្វីមួយដែលចូលចិត្ត ។ល។ (១ ធីម៉ូថេ ៥:៨) ។
- ថ្វាយបង្គំរួមជាមួយក្រុមគ្រួសារជារៀងរាល់ថ្ងៃ គឺអធិស្ឋានជាមួយគ្នា និង រិះគិតពីព្រះបន្ទូលព្រះជាម្ចាស់ ។ ឪពុកត្រូវឃ្វាលក្រុមគ្រួសាររបស់ខ្លួន (អេភេសូ ៥:១៩-២១, ៦:៤) ។

បើសិនជាប្តីប្រពន្ធមានការផិតក្បត់គ្នា យើងជួយពួកគេអោយ

- ទទួលដឹងថា ពួកគេបានប្រព្រឹត្តអំពើផិតក្បត់ ដូច្នេះ ត្រូវកែប្រែចិត្តគំនិត និង ទទួលការលើកលែងទោស ហើយទុកចិត្តថា ប្តីប្រពន្ធពិតជាអាចជានានឹងគ្នាបានមែន ។

សញ្ញាជាក់ស្តែង	**មូលហេតុ ដែលជាឫសគល់លាក់កំបាំង**
ការភ័យខ្លាចខ្លាំងម្តងៗ មិនអាចទប់ចិត្តបាន	- អាត្មានិយម និង មានអំពើបាបលាក់ទុក មិនសារភាព ។ - មិនអាចទទួលសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ ព្រោះឪពុកម្តាយមិនបានបង្ហាញសេចក្តីស្រឡាញ់ចំពោះគាត់ កាលពីគាត់នៅវ័យកុមារ ។
ចុកពោះ និង ឈឺក្បាលជាច្រើនលើកច្រើនសា	- ព្រួយចិត្ត ដោយសារជំពាក់លុយគេច្រើន ។ - ភ័យខ្លាចក្រ ដូចកាលនៅក្មេង ដែលធ្លាប់រងទុក្ខខ្លាំង ។
យុវជនរឹងចចេស មិនស្តាប់បង្គាប់	- ឪពុកម្តាយមិនចាប់អារម្មណ៍នឹងគាត់ ។ - ឪពុកយុវជននោះ អន់ចិត្តនឹងឪពុករបស់គាត់ ដែលវាយគាត់ កាលគាត់នៅពីក្មេង ។

អ្នកផ្តល់ដំបូន្មានខ្លះ ជួយមនុស្សអោយអាចរកឃើញឫសគល់ជ្រៅបំផុតនៃបញ្ហាមួយរបស់មនុស្សនោះ ដើម្បីជួយដោះស្រាយបញ្ហានោះ ។ កិច្ចការនេះ មិនស្រួលធ្វើប៉ុន្មានទេ ។ ប៉ុន្តែ យ៉ាងតិចក៏ត្រូវខិតខំជួយមនុស្សទទួលដំបូន្មាន ឱ្យទទួលស្គាល់ពីការប្រព្រឹត្តខ្លះ និង អារម្មណ៍ខ្លះរបស់គាត់ រួចរៀបចំផែនការដើម្បីដោះស្រាយបញ្ហានោះដែរ ។ តើយើងណែនាំអោយមនុស្សនោះ វាយតំលៃការប្រព្រឹត្ត និង អារម្មណ៍របស់គាត់ ដោយរបៀបណា ? ។

ដោយការអធិស្ឋាន ការចេះពឹងលើការដឹកនាំរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ សេចក្តីស្រឡាញ់ ការអត់ធ្មត់ ភាពម៉ឺងម៉ាត់ បទពិសោធន៍ការចេះសួរសំនួរល្អ។ និង ការចេះស្តាប់ នឹងជួយអ្នកអោយអាចរកឃើញឫសគល់នៃបញ្ហា ។ ក្នុងករណីពិបាក។ អ្នកផ្តល់ដំបូន្មានត្រូវការជួបជាមួយមនុស្ស ដែលត្រូវទទួលដំបូន្មានច្រើនដង ។

ខាងក្រោមនេះ មានបច្ចេកទេសក៍ និង វិធីផ្តល់ដំបូន្មានដល់អ្នកឯទៀត :

- ណែនាំមនុស្សអោយអាចរៀបរាប់ និង វិភាគមើលពីការប្រព្រឹត្ត អាកប្បកិរិយា និង អារម្មណ៍ ដែលគាត់មានសព្វថ្ងៃនេះ ។

ការឈ្លោះប្រកែក ការប្រចំណ្ឌ និង ការមិនយល់ចិត្តគ្នារវាងប្តីប្រពន្ធ

យើងជួយប្តីប្រពន្ធអោយចេះ :

- ស្តាប់ និង គិតគូរពិចារណាអំពីពាក្យសំដី ដែលគួស្រករខ្លួននិយាយ ដើម្បីសំដែងពីការមិនពេញចិត្ត ។ អ្នកទាំងពីរត្រូវនិយាយត្រង់ៗជាមួយគ្នា ដោយស្មោះត្រង់ (អេភេសូ ៤:២៥) ។
- គោរព និង គិតគូរពីអារម្មណ៍គ្នាទៅវិញទៅមក (ភីលីព ២:១-១១) ។
- អត់ទោសដោយគ្មានចិត្តគុំគួន ឬ ខឹងច្រឡោត (អេភេសូ ៤:៣១-៣២) ។
- កុំទុកកំហឹងរហូតដល់ថ្ងៃលិចនោះឡើយ ដើម្បីកុំអោយអារក្សមានឱកាសល្បួងបាន (អេភេសូ ៤:២៦-២៧) ។
- ប្រពន្ធត្រូវចុះចូលនឹងប្តីរបស់ខ្លួន (អេភេសូ ៥:២២-២៤) ។

ឆ្ពោះចិត្តអត់ទោស

ក្នុងករណីនេះ អ្នកផ្តល់ដំបូន្មានជួយមនុស្សនោះ អោយអាចជានានឹងអ្នកដទៃវិញ ។ អាចប្រើ ម៉ាថាយ ៥:២៣-២៤ ឬ អេភេសូ ៤:៣២ ដើម្បីជួយពួកគេអោយចេះអត់ទោសអោយអស់អ្នកណាដែលបានធ្វើខុសមកលើពួកគេ ។



- សួរសំណួរល្អៗ ដើម្បីអាចរកឃើញឫសគល់នៃបញ្ហា ដែលអាចទាក់ទងនឹងហេតុការណ៍ ដែលគាត់ធ្លាប់ឆ្លងកាត់ពីមុនមក ។ សួរសំណួរខាងក្រោមនេះខ្លះ ដើម្បីរកអោយឃើញថាក្នុងជីវិតគាត់មានរបួសផ្លូវចិត្តខ្លាំង ឬអត់ ។
  - តើអ្នកមានទំនាក់ទំនងដូចម្តេច ជាមួយឪពុកម្តាយអ្នក ?
  - តើកាលអ្នកនៅពីតូច ដែលមានមនុស្សធំ នៅក្នុងគ្រួសារអ្នក រំលោភអ្នកដែរឬទេ ?
  - តើអ្នក ឬ សមាជិកគ្រួសារអ្នក ដែលធ្លាប់ឆ្លងកាត់សង្គ្រាមដែរឬទេ ?
  - តើឪពុកម្តាយអ្នកលែងលះគ្នាឬ ?
  - តើឪពុកអ្នករំលោភលើសិទ្ធិម្តាយអ្នកដែរឬទេ ?
  - តើមានសមាជិកគ្រួសារអ្នកណាម្នាក់ប្រមឹកស្រា ឬ ឈ្លក់នឹងល្បែងស៊ីសងដែរឬទេ ?
  - តើសមាជិកគ្រួសាររបស់អ្នកនិយាយគ្នាទៅវិញទៅមកដោយសុភាពរាបសា ឬ ដោយកំហឹង ?
  - តើឪពុកម្តាយអ្នកមានយកអ្នកទៅឱ្យអ្នកដទៃណាម្នាក់ទៅចិញ្ចឹមដែរឬទេ ?

- តើអ្នកដែលឈឺខ្លាំងដែរឬទេ ?
- តើនៅក្នុងគ្រួសាររបស់អ្នក មានកាន់អំពើអាបធ្មប់ដែរ ឬទេ ?
- ។ល។ ។

- សូមសាកល្បងធ្វើការប្រជុំក្រុមតូចៗ ។ សមាជិកទាំងអស់ របស់ក្រុមអាចលើកទឹកចិត្តគ្នាទៅវិញទៅមក ។ អញ្ជើញពួក គេអោយទទួលខុសត្រូវចំពោះគ្នាទៅវិញទៅមក ដើម្បីអោយ ពួកគេអាចសុខចិត្តកែប្រែអាកប្បកិរិយា និង ការប្រព្រឹត្តរបស់ ពួកគេ ។

- មិនត្រូវសួរសំនួរ ដែលពួកគេអាចឆ្លើយតែ « បាទ » ឬ « ចាំ » នោះទេ ។ ត្រូវចេះសួរសំនួរ ដែលនាំអោយគេ ឆ្លើយរៀបរាប់ពិស្តារ ។ នេះជាសំនួរដែលគ្មានប្រសិទ្ធិភាព « តើឪពុកម្តាយរបស់អ្នក មានធ្វើអាក្រក់មកលើអ្នកឬទេ ? » ។ ឯសំនួរដែលមានប្រយោជន៍គឺ « តើឪពុកម្តាយអ្នកប្រព្រឹត្ត ដូចម្តេចចំពោះអ្នក ? » ។

- ត្រូវស្តាប់ដោយចិត្តមេត្តា និង ខំយល់ចិត្តគេ គឺ « *ចូរអរ-សប្បាយជាមួយអស់អ្នកដែលអរសប្បាយ ចូរយំសោកជា មួយអស់អ្នកដែលយំសោក* » (រ៉ូម ១២:១៥) ។

កុមារឆ្មានវិន័យ ឬ យុវជនរឹងចចេសដែលមិនស្តាប់បង្គាប់

យើងជួយឪពុកម្តាយអោយអាច :

- ចិញ្ចឹមកូនដោយសេចក្តីស្រឡាញ់ ម៉ឺងម៉ាត់ និង ដោយអប់រំ ប្រៀនប្រដៅត្រឹមត្រូវ និង សមល្មម (អេភេសូ ៦:៤) ។
- អត់ទោសអោយយុវជនដែលមិនស្តាប់បង្គាប់ និង ត្រៀមខ្លួន អប់រំស្តារពួកគេឡើងវិញ នៅពេលដែលពួកគេកែប្រែចិត្ត គំនិត (លូកា ១៥:១១-៣២) ។

យើងលើកទឹកចិត្តកុមារ និង យុវជនដោយអំណត់ និង ដោយ សេចក្តីស្រឡាញ់ អោយ :

- គោរព និង ស្តាប់បង្គាប់ឪពុកម្តាយ (អេភេសូ ៦:១-៣) ។
- រៀនផ្នែកខ្លះរបស់សៀវភៅសុភាសិត ដែលបង្រៀនយុវជន អោយចេះគោរពឪពុកម្តាយ និង ព្រះបន្ទូលព្រះជាម្ចាស់ ។

ដើម្បីចេះពីរបៀបណែនាំកូនៗអោយបានច្រើនជាងនេះ សូមមើល កូនសៀវភៅសំរាប់បង្ហាត់បង្រៀនគ្រួគង្វាល ទី ៥៦ « ក្រុមគ្រួសារ របស់ខ្ញុំ » ។

© Project WorldReach © SEAN

- បន្តជួបប្រជុំជាមួយពួកអ្នកដែលជួយកសាងគេ អោយជីវិតឡើងក្នុងព្រះជាម្ចាស់ និង ជាមួយពួកអ្នកដែលធ្លាប់ជាមនុស្សញៀនឯទៀត ដើម្បីលើកទឹកចិត្ត និង គាំទ្រគ្នាទៅវិញទៅមក (ហេប្រឺ ១០:២៤-២៥) ។

បញ្ហាដោយសារលុយ

យើងជួយពួកអ្នក ដែលកំពុងខិតខំដោះស្រាយបញ្ហាខាងប្រាក់កាសរបស់ពួកគេ អោយ :

- ថ្វាយកិត្តិយសទៅព្រះជាម្ចាស់ ដោយដាក់ដង្វាយដប់ភាគរយ (សុភាសិត ៣:៩-១០) ។
- ចេះស្កប់ចិត្តនឹងអ្វី ដែលព្រះជាម្ចាស់ប្រទានអោយពួកគេ (ភីលីព ៤:១១) ។
- រៀបចំគំរោងថវិកាជាមួយគូស្រករបស់ខ្លួន សំរាប់ក្រុមគ្រួសារ គឺកំណត់ប្រាក់ចំណាយ ស្របទៅតាមចំណូលរបស់ខ្លួន (លូកា ១៤:២៨) ។
- ត្រូវទិញតែរបស់ដែលត្រូវការចាំបាច់ ត្រូវបង់វិក័យប័ត្រភ្លាមៗ និង ចៀសវាងកុំទិញជឿឱ្យសោះ (រ៉ូម ១៣:៥-៨) ។

- មិនត្រូវកាន់ជើងម្ខាងៗ ប្រកាន់បក្សពួក ឬ ធ្វើការទិតៀនអ្នកនេះ ឬ អ្នកនោះទេ ។ យើងមិនមែនធ្វើកិច្ចការបំរើនេះដើម្បីថ្កោលទោសគេទេ គឺយើងធ្វើដើម្បីជួយអ្នកដទៃអោយអាចដោះស្រាយបញ្ហារបស់ពួកគេបាន ស្របតាមគោលការណ៍នៃព្រះគម្ពីរទៅវិញទេ ។
- និយាយជាមួយអ្នកដែលមានបញ្ហាដោយផ្ទាល់ មិននៅចំពោះមុខមនុស្សឯទៀតទេ ។ ប៉ុន្តែ ក្នុងករណីផ្តល់ដំបូន្មានទៅមនុស្សដែលមានភេទផ្សេង ត្រូវតែមានមនុស្សម្នាក់ទៀតនៅជាមួយ ហើយអ្នកចូលរួមទីបីនោះ គួរតែជាមនុស្សដែលមានភេទដូចមនុស្ស ដែលត្រូវទទួលដំបូន្មាន ។ ទោះបីជាអ្នកទីបី មិនចូលនិយាយពិភាក្សា ក៏អ្នកនោះអាចអធិស្ឋានបានដែរ ។
- អ្នកផ្តល់ដំបូន្មាន និង អ្នកដែលទៅជាមួយគាត់ ត្រូវតែរក្សាសេចក្តីដែលបានពិភាក្សាជាមួយមនុស្ស ឬ គូស្វាមីភរិយាដែលទទួលដំបូន្មាន ទុកជាការសម្ងាត់រហូត ។ គ្រូគង្វាលមិនត្រូវនិយាយបន្តនូវអ្វី ដែលគេប្រាប់គាត់ជាសម្ងាត់ ជាដាច់ខាត ។

- ជួនកាលអ្នកអាចស្តាប់ឮរឿងរ៉ាវ ដែលធ្វើអោយអ្នករន្ធត់ចិត្ត ដែលអ្នកស្មានមិនដល់ ។ ប៉ុន្តែ អ្នកមិនត្រូវដាក់ទោសអ្នកនោះទេ គឺអ្នកត្រូវទទួលគេ ទុកជាមនុស្សដែលព្រះជាម្ចាស់ស្រឡាញ់ទៅវិញ ។ ព្រះអង្គចង់ឱ្យពួកគេបានប្រសើរបំផុត ហេតុនេះ យើងត្រូវទូន្មាន និង អធិស្ឋានអោយត្រូវទៅតាមការទាំងនេះ ។
- បើសិនជាអ្នកគិតថា អ្នកដែលត្រូវទទួលដំបូន្មាននោះ ត្រូវការជំនួយពិសេស ត្រូវសុំអោយមនុស្សនោះយល់ព្រមសិនចាំនាំគាត់ទៅជួបពិភាក្សាជាមួយអ្នកឯកទេសណាម្នាក់ទៀត ។
- នៅពេលផ្តល់ដំបូន្មានដល់ប្តីប្រពន្ធ បើសិនជាគេទាំងពីរនាក់ឈ្លោះគ្នានៅមុខអ្នក ដំបូង ត្រូវធ្វើយ៉ាងណាអោយគេទាំងពីរនាក់ស្តាប់គ្នាទៅវិញទៅមក ។ ប្តីប្រពន្ធអាចផ្សះផ្សាគ្នាបាន លុះត្រាតែគេម្នាក់ៗដឹងពីគំនិតរបស់អ្នកម្ខាងទៀត ។ ឧទាហរណ៍ សូមសួរទៅប្តីថា÷ «តើប្រពន្ធអ្នក ទើបនឹងនិយាយថាម៉េចអំបាញ់មិញ ? ទោះបីជាអ្នកមិនយល់ព្រមនឹងប្រពន្ធអ្នកក្តី ខ្ញុំសូមអោយអ្នកនិយាយតាមពាក្យគាត់ឡើងវិញ ព្រោះខ្ញុំចង់ដឹងថា អ្នកយល់គំនិតគាត់ដែរឬអត់ »។

- គោរពកោតខ្លាចតែព្រះជាម្ចាស់ និង ភ័យខ្លាចពីលទ្ធផលនៃការមិនស្តាប់តាមព្រះអង្គ (សុភាសិត ១:៧) ។
- ទុកចិត្តលើសេចក្តីស្រឡាញ់អស់កល្បរបស់ព្រះជាម្ចាស់ ដើម្បីអាចឈ្នះលើការភ័យខ្លាច និង លើទំលាប់អាក្រក់ (១ យ៉ូហាន ៤:១៨) ។
- យល់ដឹង និង ទទួលស្គាល់តម្លៃរបស់ខ្លួនជាមនុស្ស ដែលព្រះជាម្ចាស់បានប្រោសលោះ និង បានបង្ហាញព្រះហឫទ័យស្រឡាញ់ចំពោះខ្លួន (រ៉ូម ៥:៨, ៨:២៨, ១ កូរិនថូស ១៥:១០) ។
- ទទួលស្គាល់ភាពទន់ខ្សោយរបស់ខ្លួន និង ប្រកាសអំពីឫទ្ធានុភាពរបស់ព្រះគ្រីស្ត ដែលនាំអោយមានជ័យជំនះ (ទំនុកតម្កើង ៣៧:៥-៧, ២ ធីម៉ូថេ ១:៧) ។
- បោះបង់ឈប់ញៀននឹងអ្វីទាំងអស់ ហើយចេញអោយឆ្ងាយពីកន្លែង ដែលអាចនាំអោយធ្លាក់ក្នុងការល្បួង ។
- ទូលសូមអោយព្រះជាម្ចាស់បំពេញខ្លួន ដោយព្រះវិញ្ញាណ-ដ៏វិសុទ្ធ ។

- ជួយពួកគេឱ្យរៀបចំពេលវេលាទៀងទាត់ សំរាប់អធិស្ឋាន និងអានព្រះគម្ពីរប្រចាំថ្ងៃ ។
- ជួយពួកគេអោយមានមិត្តភក្តិថ្មីៗ ដែលនឹងជួយពួកគេមិនឱ្យធ្លាក់ក្នុងការល្បួង ។
- ជួយពួកគេឱ្យស្វែងរកគោលដៅថ្មីៗ ដែលមកពីព្រះជាម្ចាស់ សំរាប់កិច្ចការបំរើព្រះជាម្ចាស់ ក្រុមគ្រួសារ ការងារ និងការសិក្សារបស់ពួកគេ ហើយជួយពួកគេអោយអនុវត្តគោលដៅទាំងនោះ ។
- អោយពួកគេចូលរួមសិក្សាព្រះគម្ពីរក្នុងក្រុមតូចមួយ ដែលមានមនុស្សជួយលើកទឹកចិត្តពួកគេ ហើយដែលពួកគេអាចមានអ្នកដឹកនាំថែរក្សាជាប្រចាំ ។

ការញៀន

យើងជួយមនុស្សដែលមានទំលាប់អាក្រក់ ឬក៏ញៀននឹងអ្វីមួយឱ្យអាចសំរេចចិត្តធ្វើតាមសេចក្តីដូចខាងក្រោមនេះ :

- ទុកចិត្តលើវត្តមាន និង ឫទ្ធានុភាពរបស់ព្រះជាម្ចាស់ (អេសាយ ៤១:១០, ហេប្រឺ ១៣:៥-៨) ។

សូមបន្តសុំអោយអ្នកទាំងពីរនិយាយតាមពាក្យអ្នកម្ខាងទៀតឡើងវិញ រហូតដល់អ្នកទាំងពីរអាចនិយាយតាមពាក្យគ្នាបានត្រឹមត្រូវ ។ ពួកគេនឹងងាយត្រូវគ្នាវិញ ពេលដែលពួកគេដឹងពីបញ្ហាគ្នាទៅវិញទៅមក ។



ត្រូវយកចិត្តទុកដាក់ស្តាប់អស់អ្នកណាដែលអ្នកត្រូវប្រដៅទូន្មាន ហើយសួរសំនួរ ដែលជួយអ្នកទាំងនោះ អោយអាចវាយតម្លៃបញ្ហារបស់ខ្លួន ។ បញ្ហាអាចដោះស្រាយបាន លុះត្រាតែរកឃើញមូលហេតុពិតនៃការព្រួយបារម្ភ ។ លើសពីនេះទៅទៀត អ្នកមានបញ្ហាត្រូវព្រមទទួលស្គាល់មូលហេតុនោះ ហើយព្រមទទួលខុសត្រូវធ្វើកិច្ចការអ្វីមួយ ដើម្បីដោះស្រាយបញ្ហានេះ ។

តើអ្នកណាត្រូវរកឃើញ និង ទទួលស្គាល់បញ្ហា ?

☐ អ្នកផ្តល់ជំបូន្មាន ។

☐ មនុស្សដែលមានបញ្ហា ដោយមានព្រះជាម្ចាស់ជួយ ។

អ្នកដែលរងទុក្ខលំបាកដោយសារមានបញ្ហា ត្រូវតែដោះស្រាយបញ្ហានោះ ។ បើសិនជាអ្នកនោះ មិនរកផ្លូវដោះស្រាយបញ្ហារបស់ខ្លួនឯងទេ បញ្ហានោះនឹងនៅតែមានដដែលជានិច្ច ។

អ្នកផ្តល់ជំបូន្មានត្រូវសួរសំនួរអំពីបញ្ហា រហូតទាល់តែពួកគេរកឃើញ :

☐ កំហឹងរបស់គាត់ ។

☐ ការកែប្រែការប្រព្រឹត្ត ឬអាកប្បកិរិយា ដែលនឹងជួយឱ្យអាចដោះស្រាយបញ្ហាបាន ។

គោលការណ៍សំរាប់ជួយអ្នកទទួលជំបូន្មានអោយអាចសំរេចកិច្ចការដែលត្រូវធ្វើ ដើម្បីដោះស្រាយបញ្ហា

គោលការណ៍ទូទៅ :

- ជួយពួកគេអោយចេះអត់ទោសដល់ពួកអ្នក ដែលបានធ្វើខុសមកលើពួកគេ ។ ពួកគេត្រូវអត់ទោសដោយជំនឿ មិនមែនដោយអារម្មណ៍ទេ ។ ជំបូង ពួកគេមានចិត្តទើសទាល់ មិនចង់ទាក់ទងជាមួយមនុស្ស ដែលធ្វើខុសមកលើពួកគេទេ ។ ប៉ុន្តែ នៅពេលដែលពួកគេទូលថ្វាយទៅព្រះជាម្ចាស់ដោយជំនឿថា ពួកគេចង់អត់ទោសមនុស្សនោះ អារម្មណ៍របស់គេនឹងកែប្រែ ។ បើគេមានបំណងចង់អត់ទោស ហើយទូលសូមអោយព្រះជាម្ចាស់ជួយ នោះព្រះអង្គនឹងធ្វើអោយពួកគេលែងមានអារម្មណ៍ផ្តេសផ្តាស ។ ពួកគេមិនត្រូវសំរេចចិត្តធ្វើអ្វីមួយតាមអារម្មណ៍របស់ខ្លួនទេ តែត្រូវធ្វើតាមព្រះហឫទ័យរបស់ព្រះជាម្ចាស់វិញ ។

- ជួយពួកគេអោយទៅសុំទោសអស់អ្នក ដែលពួកគេបានធ្វើខុសទៅលើ ឬ មានទំនាស់ជាមួយអ្នកទាំងនោះ (ម៉ាថាយ ៥:២៣-២៤) ។

© Project WorldReach © SEAN

ត្រូវជួយអ្នកដែលមានបញ្ហានោះអោយរៀបចំផែនការ និង កិច្ចការ ដែលគាត់ត្រូវធ្វើ ។ អ្នកត្រូវបន្តផ្តល់ដំបូន្មានច្រើនដងទៀត រហូតដល់អ្នកដែលមានបញ្ហានោះ បានដោះស្រាយបញ្ហា និង ការពារមិនអោយមានបញ្ហាដូចនោះកើតមានឡើងវិញទៀត ។ នៅពេលដែលអ្នកជួបប្រជុំជាមួយអ្នកទទួលដំបូន្មាន អ្នកត្រូវជួយអ្នកនោះរៀបចំគោលដៅសំរាប់ដោះស្រាយបញ្ហារបស់គាត់ ដើម្បីឱ្យគាត់អាចសំរេចគោលដៅនោះ មុនពេលគាត់មកជួបប្រជុំជាមួយអ្នកលើកក្រោយទៀត ។ បើសិនជាបញ្ហានោះ ប៉ះពាល់ដល់សាច់ញាតិរបស់សាមីជន អ្នកក៏ត្រូវផ្តល់ដំបូន្មានដល់អ្នកទាំងនោះដែរ ហើយត្រូវរួបរួមគ្នាជាមួយអ្នកទាំងនោះ ដើម្បីរៀបចំជំហានសំរាប់ដោះស្រាយបញ្ហា ។

សូមកុំចំណាយពេលឥតប្រយោជន៍ជាមួយមនុស្សអាត្មានិយម ដែលពិតជាមិនមែនចង់ដោះស្រាយបញ្ហារបស់ខ្លួនទេ គឺគ្រាន់តែចង់អោយអ្នកផ្តល់ដំបូន្មាន យកចិត្តទុកដាក់គ្រប់យ៉ាងចំពោះខ្លួនគេប៉ុណ្ណោះ ។ បើសិនជាមនុស្សគ្រាន់តែចង់អោយមានអ្នកណាម្នាក់លួងលោមចិត្តខ្លួន តែមិនចង់ដោះស្រាយបញ្ហារបស់ខ្លួនទេ នោះបញ្ហារបស់គេនៅតែមិនអាចដោះស្រាយបានដដែល ។ យើងត្រូវទូលសូមអោយព្រះជាម្ចាស់ជួយយើង អោយមានប្រាជ្ញា ដើម្បីអាចមើលស្គាល់មនុស្សប្រភេទនេះបាន ។

តាមធម្មតា ពាក្យរ៉ាយរ៉ាប់ប្រាប់ដំបូង មិនបង្ហាញអោយដឹងពីបុរសគេល់របស់បញ្ហាទេ ។ ពាក្យទាំងនោះច្រើនតែបង្ហាញពី :

☐ លទ្ធផលនៃបញ្ហា ។

☐ មូលហេតុនៃបញ្ហា ។

ដើម្បីអាចរកឃើញមូលហេតុជាបុរសគេល់ជ្រៅ អ្នកផ្តល់ដំបូន្មានត្រូវ :

☐ សួរសំនួរឈ្លាសវៃ និង ស្រាវជ្រាវជាច្រើន ។

☐ អធិប្បាយវែងៗ ។

ក្រោយពីបានសួរសំនួរហើយ អ្នកផ្តល់ដំបូន្មានត្រូវ :

☐ ស្តីបន្ទោស បើសិនជាមនុស្សនោះមិនអាចឆ្លើយបាន ។

☐ ស្តាប់ដោយអំណត់ ។

គន្លឹះពីរសំរាប់រកអោយឃើញឫសគល់នៃបញ្ហាគឺ « សួរ » និង « ស្តាប់ » ។ បើសិនជាអ្នកទទួលជំបួន្ទាន បង្វែរទៅនិយាយពីអ្វីផ្សេងវិញ ត្រូវចេះនាំគេដោយសុភាពរាបសាអោយនិយាយពីរឿងមុនវិញ ដោយមិនធ្វើឱ្យគេស្មានថា អ្នកមិនចង់ស្តាប់មតិយោបល់របស់ពួកគេទេ ។

ឧទាហរណ៍ អំពីសំនួរដែលជួយអោយអាចរកឃើញឫសគល់ជ្រៅរបស់បញ្ហា :

- « តើអ្នកដឹងថា អ្វីដែលបណ្តាលអោយអ្នកមានរបួសផ្លូវចិត្តជ្រៅយ៉ាងនេះ ? » ។
- « តើអ្នកមានអារម្មណ៍ខ្លាំងចង់ផឹកស្រា នៅក្នុងកាលៈទេសៈណា ? » ។
- « តើអ្នកមានបានទៅអោយគ្រូពេទ្យពិនិត្យ ដើម្បីអោយដឹងថាអាចមានមូលហេតុទាក់ទងនឹងរូបកាយឬទេ ? តើគ្រូពេទ្យថាដូចម្តេច ? » ។
- « ហេតុអ្វីបានជាអ្នកនៅតែទៅដើរលេងជាមួយពួកអ្នក ដែលនាំអ្នកអោយផឹកស្រាទៀត ? » ។

ព្រះជាម្ចាស់ជួយយើង តែនៅពេលដែលយើងធ្វើតាមព្រះហឫទ័យរបស់ព្រះអង្គប៉ុណ្ណោះ ។



ត្រូវអធិស្ឋានជាប់ជានិច្ចជាមួយអ្នកទទួលជំបួន្ទាន ដើម្បីអោយគេអាចដឹងពីព្រះហឫទ័យរបស់ព្រះជាម្ចាស់ និង ទទួលព្រះ-ហឫទ័យនោះបាន ។

យកសេចក្តីបង្រៀនក្នុងព្រះបន្ទូលរបស់ព្រះជាម្ចាស់មកអនុវត្ត ដើម្បីដោះស្រាយបញ្ហា

ជួយមនុស្ស ឬ គ្រួសារដែលមានបញ្ហា ឱ្យចេះយកសេចក្តីបង្រៀនក្នុងព្រះបន្ទូលរបស់ព្រះជាម្ចាស់មកអនុវត្ត ដើម្បីដោះស្រាយបញ្ហារបស់ពួកគេផ្ទាល់ ។ បើសិនជាក្នុងព្រះគម្ពីរគ្មានចែងអំពីបញ្ហាដូចនេះទេ ត្រូវបង្រៀនអំពីគោលការណ៍ ដែលត្រូវនឹងបញ្ហានេះ ។

ដើម្បីជួយមនុស្សអោយអាចគិតសាជាថ្មីឡើងវិញ សូមអោយគេសិក្សាអេភេសូ ៤:១៧-៣២ និង កូឡូស ជំពូក ៣ ។

- «ហេតុអ្វីបានជាអ្នកមិនទុកចិត្តប្រពន្ធខ្លួនខ្លះទៅ ដើម្បីអាចប្រាប់នាងពីរឿងបំណុល ដែលអ្នកជំពាក់គេនោះ ? » ។
- «ហេតុដូចម្តេច បានជាអ្នកមិនអាចអត់ទោសចំពោះកំហុសដែលប៉ុនបានធ្វើនោះ ? » ។
- «ហេតុអ្វីបានជាអ្នកមិនអប់រំកូនៗ ? » ។
- «ហេតុអ្វីបានជាអ្នកខ្លាចប្តីម្ល៉េះ ? » ។
- «តើអ្នកចាប់ផ្តើមមានការឈឺចាប់ខ្លាំងនេះពីពេលណាមក ? តើអ្នកគិតថា អ្នកឈឺចាប់នេះបណ្តាលមកពីអ្វី ? » ។
- «ប្រហែលជាអ្នកមិនអាចអត់ទោសឱ្យឪពុកអ្នក ដោយសារខ្លួនអ្នកផ្ទាល់ មិនបានទទួលការអត់ទោសរបស់ព្រះគ្រីស្តពេញលេញនៅឡើយ ។ ហេតុអ្វីបានជាអ្នកមិនទាន់សុំអោយព្រះអង្គលើកលែងទោសដល់អ្នក ? » ។
- «តើអ្នកចាប់ផ្តើមមានអារម្មណ៍ថាខ្លួនមិនល្អ និង គ្មានបានការដោយសារអ្វី ? » ។

លើឈើឆ្កាងរបស់ព្រះអង្គ ជាភស្តុតាង ។ ត្រូវធ្វើអោយពួកគេទុកចិត្តថា ព្រះបិតាលើកលែងទោសអោយគេ និង ប្រទានជីវិតអស់កល្បអោយគេក្នុងព្រះគ្រីស្ត ដែលមានព្រះជន្មរស់ឡើងវិញ ។

គ្រីស្តជនដែលបានធ្វើបាប ត្រូវលន់តួសារភាពដោយស្មោះត្រង់ថ្វាយព្រះជាម្ចាស់ អំពីអំពើបាបដែលខ្លួនបានធ្វើ ហើយនៅតែទុកចិត្តថា ព្រះអង្គជំរះសំអាតខ្លួន និង លើកលែងទោសអោយខ្លួន ។ អ្នកមិនទាន់ជឿ ត្រូវជឿទុកចិត្តថា ព្រះគ្រីស្តអាចលើកលែងទោសអំពើបាបបាន ។ អ្នកផ្តល់ដំបូន្មានល្អ ជួយមនុស្សអោយមានចិត្តទៀងត្រង់នៅចំពោះព្រះជាម្ចាស់ ។ សូមអាន ១ យ៉ូហាន ១:៨-២:២ ។

បើសិនជាអ្នកដែលទទួលដំបូន្មាន ជាអ្នកជឿស្មោះត្រង់ អ្នកត្រូវលើកទឹកចិត្តគាត់ ឱ្យប្រតិបត្តិតាមព្រះហឫទ័យព្រះជាម្ចាស់ចំពោះបញ្ហារបស់គាត់នោះ ទោះជាព្រះហឫទ័យនោះយ៉ាងណាក៏ដោយ ។

«ឱព្រះបិតាអើយ ! ប្រសិនបើបាន សូមអោយពែងនៃទុក្ខលំបាកនេះចេញឆ្ងាយពីទូលបង្គំទៅ ប៉ុន្តែ សូមកុំធ្វើតាមបំណងទូលបង្គំឡើយ គឺសូមឱ្យបានសំរេចតាមព្រះហឫទ័យរបស់ព្រះអង្គវិញ » ។

(ម៉ាថាយ ២៦:៣៩)

- «តើពេលអ្នកនៅតូច ឪពុកអ្នកប្រព្រឹត្តចំពោះអ្នកដូចម្តេច ? តើឪពុកអ្នក ឬ អ្នកណាផ្សេងម្នាក់ទៀត មានដែលរំលោភសិទ្ធិអ្នក ពេលអ្នកនៅតូច ដែលបណ្តាលអោយអ្នកលែងអាចទុកចិត្តមនុស្សប្រុសទាំងអស់បាន ដែរឬទេ ? » ។
- «តើអ្នកនៅតែចង់បំពេញចិត្តឪពុកម្តាយអ្នក ដោយទុកអោយគាត់ល្បួកដៃចូលក្នុងរឿងប្តីប្រពន្ធរបស់អ្នកដែរឬទេ ? ហេតុអ្វី ? » ។
- «ពេលអ្នកនៅតូច តើនៅក្នុងក្រុមគ្រួសាររបស់អ្នក យ៉ាងម៉េចដែរ ? មានបញ្ហាដូចម្តេចខ្លះ ? » ។
- «នៅពេលដែលអ្នកនឹកឃើញពីឪពុក ឬ ម្តាយអ្នក តើអ្នកមានអារម្មណ៍យ៉ាងណាដែរ ? » ។
- «អ្នកនិយាយថា កាលពីអ្នកនៅតូច ឪពុកអ្នកជាមនុស្សកាចណាស់ ហើយប្រើអំណាចខ្លាំងក្នុងគ្រួសារ ។ តើនេះជាមូលហេតុ ដែលធ្វើអោយអ្នកផ្ទាល់ កាចជាមួយក្រុមគ្រួសារអ្នកដូចឪពុកអ្នកដែរ ដែរឬទេ ? » ។
- «តើអ្នកចង់អោយព្រះយេស៊ូគ្រីស្ត ជួយរំដោះអ្នក ឱ្យរួចពីច្រវាក់ដែលចងអ្នកជាប់ តាំងពីអ្នកនៅតូចដែរឬទេ ? » ។

- «ដើម្បីអោយអ្នក និង គ្រួសាររបស់អ្នកមានសេចក្តីសុខ តើអ្នកយល់ព្រមអត់ទោសអោយឪពុកអ្នក ដែលបានធ្វើឱ្យអ្នកមានរបួសទាំងនេះដែរឬទេ ? តើអ្នកមានបំណងចង់លន់តួសារភាពអំពើបាបរបស់អ្នកទៅព្រះគ្រីស្ត ដើម្បីអោយអ្នកអាចអត់ទោសអោយអ្នកឯទៀត ដែរឬទេ ? » ។

ណែនាំពួកគេអោយសំរុះសំរួលទំនាក់ទំនងរបស់ពួកគេអោយជានានឹងព្រះជាម្ចាស់

សេចក្តីត្រូវការធំបំផុតរបស់មនុស្ស គឺមានសេចក្តីសុខសាន្តជាមួយនឹងព្រះជាម្ចាស់ ។ បន្ទាប់មក មានសេចក្តីសុខសាន្តជាមួយខ្លួនឯងផ្ទាល់ និង ជាមួយមនុស្សឯទៀត ។

បញ្ហាផ្ទាល់ខ្លួន និង បញ្ហារវាងប្តីប្រពន្ធអាចនឹងដោះស្រាយបាន នៅពេលដែលអ្នកមានបញ្ហា លន់តួសារភាពអំពើបាបរបស់ខ្លួនថ្វាយព្រះជាម្ចាស់ ហើយអ្នកនោះទុកចិត្តថាព្រះជាម្ចាស់លើកលែងទោសអោយគេ និង ស្រឡាញ់គេ ។

ចំពោះមនុស្សដែលមិនទាន់ស្គាល់ព្រះគ្រីស្ត ត្រូវធ្វើអោយពួកគេទុកចិត្តថាព្រះគ្រីស្តស្រឡាញ់ពួកគេ ដោយមានពលិកម្មសុគតនៅ